# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាប្រសិទ្ធីពរលើប្រេងនៅព្រះសហគមន៍សន្តសិលា និងសន្តប៉ូល
# ភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០
# យើងចូលនៅក្នុងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ដោយអធិដ្ឋាន

**អត្ថបទទី១៖ អេសាយ ៦១,១-៣ក.៦ក.៨ខ**

ព្រះអម្ចាស់មានព្រះបន្ទូលថា យើងចូលចិត្តយុត្តិធម៌ ហើយស្អប់ការជំរិតជិះជាន់ណាស់។ អស ៦១,៨ក

**អត្ថបទទី២៖ វិវរណៈ ១,៥-៨**

មនុស្សទាំងអស់នឹងឃើញព្រះអង្គ សូម្បីតែអស់អ្នកដែលបានចាក់ទម្លុះព្រះអង្គ ក៏នឹងឃើញព្រះអង្គដែរ។ វវ ១,៧ខ

**ដំណឹងល្អ៖ លូកា ៤,១៦-២១**

ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ហេតុការណ៍ដែលមានចែងទុកក្នុងគម្ពីរ ដូចអ្នករាល់គ្នាទើបនឹងស្តាប់អំបាញ់មិញ បានសម្រេចជារូបរាងនៅថ្ងៃនេះហើយ»។ លក ៤,២១

បងប្អូនជាទីស្រឡាញ់!

ប៉ុន្មានថ្ងៃកន្លងមក យើងអង្គុយសម្លឹងមើលអ្វីដែលបានកើតឡើងនៅក្នុងពិភពលោក នៅប្រទេសកម្ពុជាយើងរដ្ឋាភិបាលបានបិទសាលារៀន បិទការជួបជុំគ្នាបែបសាសនា បិទកន្លែងកំសាន្តនានា...។ យើងកំពុងទន្ទឹងរង់ចាំច្បាប់ប្រកាសអាសន្ន ដែលរដ្ឋាភិបាលកំពុងតែរៀបចំហើយ និងយើងទន្ទឹងរង់ចាំរបៀបដែលអនុវត្តនៅលើទឹកដីកម្ពុជាយើង។

ឆ្នាំនេះ ប្រសិទ្ធពរលើប្រេងជាពេលវេលាមួយប្លែក រាល់ឆ្នាំជាពេលវេលាដែលយើងពោរពេញដោយអំណរសប្បាយ មានបូជាចារ្យមកពីទាំងបីភូមិភាគ។ យើងមានពេលពេញមួយថ្ងៃរួមគ្នា ដើម្បីជួបជុំគ្នា ញ៉ាំជាមួយគ្នា រិះគិតជាមួយគ្នាអំពីការងារ ចែករំលែកមិត្តភាព អភិបូជារួមគ្នា ជាឱកាសមួយសម្រាប់លោកបូជាចារ្យប្រកាសពាក្យសច្ចាសាជាថ្មី។ ជាពេលវេលាដែលគ្រីស្តបរិស័ទជូនពរ និងថ្លែងអំណរគុណដល់បូជាចារ្យទាំងអស់ ដែលបម្រើដោយធ្វើជាគ្រូគង្វាលអស់ពីកម្លាំងកាយកម្លាំងចិត្ត។ លោកអភិបាល ប៊្រុយណូ និងអភិបាល គីគេ បានឯកភាពឲ្យខ្ញុំថ្វាយអភិបូជាប្រសិទ្ធីពរលើប្រេងថ្ងៃនេះ ដោយលើកការជួបជុំគ្នារបស់បូជាចារ្យទាំងអស់ ជាមួយគ្រីស្តបរិស័ទមួយចំនួនដែរ ដើម្បីឲ្យបូជាចារ្យមានឱកាសប្រកាសពាក្យសច្ចាសាជាថ្មីនៅតាំងគោក នៅពេលខាងមុខតែអត់ដឹងនៅពេលណា ដោយសារយើងឃើញ បរិយាកាស កាលៈទេសៈ ប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែយើងដឹងថាប៉ុន្មានខែទៀត យើងមានឱកាសជួបជុំគ្នានៅតាំងគោក ដើម្បីរួមគ្នាអធិដ្ឋាន និងអរព្រះគុណព្រះជាម្ចាស់ដែលរំដោះយើងពីកូវីដ១៩ ដែលណែនាំ

ឲ្យយើងចូលក្នុងឆ្នាំមហាករុណាទិគុណរបស់ព្រះអង្គ និងដើម្បីឲ្យប្រកាសពាក្យសច្ចារបស់បូជាចារ្យសាជាថ្មី និងជួបជាមួយគ្រីស្តបរិស័ទដែលជាហ្វូងចៀមរបស់យើងខ្ញុំ។

តាមពិតថ្ងៃនេះ ខ្ញុំសុំព្រះជាម្ចាស់ប្រសិទ្ធីពរលើប្រេង ខ្ញុំគិតថាប្រេងទាំងបីនេះ ណែនាំឲ្យយើងចូលសាជាថ្មីនៅក្នុងសារៈសំខាន់នៃជីវិតរបស់យើង។ សម្រាប់យើងដែលរស់នៅក្នុងពិភពមួយដែលកំពុងភ័យខ្លាច ដែលមានអ្នកស្លាប់យ៉ាងច្រើនពីមួយថ្ងៃទៅមួយថ្ងៃ ពេលនេះយើងនៅក្បែរប្រេងដែលមានជីវិត។ យើងមានប្រេងសម្រាប់អ្នកជំងឺ យើងមានប្រេងសម្រាប់បងប្អូនទទួលការអប់រំជំនឿ និងយើងមានប្រេងពិសិដ្ឋដែលជាប្រេងគ្រីស្មា ដើម្បីធ្វើពិធីអគ្គសញ្ញាដូចជា អគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្ងាស និងអគ្គសញ្ញាតែងតាំងជាបូជាចារ្យឬជាឧបដ្ឋាក ឬជាអភិបាល។ ខ្ញុំគិតថាសម្រាប់យើងជាគ្រីស្តបរិស័ទ នៅពេលនេះយើងទទួលកម្លាំងកាយកម្លាំងចិត្តថ្មីពីព្រះយេស៊ូ ដោយដឹងថាព្រះយេស៊ូជាព្រះគ្រីស្ត។ ព្រះយេស៊ូ ជាព្រះគ្រីស្តដែលទទួលប្រេងអភិសេក ដែលព្រះអង្គលាបទៅលើព្រះអង្គ និងប្រេងអភិសេកនេះនៅពេលនេះតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈអគ្គសញ្ញានៃជីវិត តាមរយៈព្រះពរសម្រាប់អ្នកដែលទទួលអប់រំជំនឿទៅជាកម្លាំងយ៉ាងជាក់ស្តែង ទៅជាជីវិតយ៉ាងជាក់ស្តែងរបស់ព្រះជាម្ចាស់ដែលយាងមក សម្រាប់យើងដែលជាព្រះសហគមន៍។

តាមពិតព្រះយេស៊ូមិនកំពុងដេកលក់ ដែលមិនអើពើដល់ពិភពលោក ដែលមិនរវីរវល់នឹងយើង ព្រះយេស៊ូដឹងច្បាស់ថាយើងនៅក្នុងកាលៈទេសៈយ៉ាងពិបាក នៅក្នុងគ្រាអាសន្ន នៅក្នុងពេលវេលាសម្ងាត់ ពេលវេលាឯកោ បីដូចជាខ្យល់ព្យុះយ៉ាងខ្លាំងមែនទែន និងណែនាំឲ្យជីវិតរបស់យើងចង់ដួល ចង់លិច ចង់បាត់អ្វីៗទាំងអស់ ឬបាត់សេចក្តីសង្ឃឹម ប៉ុន្តែយើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង និងណែនាំឲ្យខ្យល់ព្យុះនៅស្ងៀមស្ងាត់។ ព្រះជាម្ចាស់អត់ដែលលះបង់ចោលប្រជារាស្ត្ររបស់ព្រះអង្គ យើងបានឃើញនៅពេលជនជាតិអ៊ីស្រាអែល បានចេញធ្វើដំណើរ៤០ឆ្នាំនៅក្នុងវាលរហោស្ថាន ទោះបីគេរអ៊ូរទាំទៅដល់ព្រះជាម្ចាស់ អត់មានទឹក អត់មានម្ហូបអាហារ ប៉ុន្តែព្រះជាម្ចាស់បានភ្ជាប់ជាមួយលោកម៉ូសេដើម្បីប្រទានទាំងនំម៉ាណា ទាំងទឹកដ៏មានជីវិតដល់ប្រជារាស្ត្ររបស់ព្រះអង្គ។

ដូច្នេះនៅពេលនេះ ក៏ព្រះជាម្ចាស់គង់នៅជាមួយយើង ជាពិសេសតាមរយៈប្រេងទាំងបីនេះ ព្រះជាម្ចាស់គង់នៅជាមួយអ្នកជំងឺ ជាពិសេសអ្នកដែលបានធ្វើពិធីគ្រាស់ហៅយ៉ាងឱឡារិក (ជំហានទី២) ដែលខ្ញុំបានលាបប្រេងហ្នឹង។ ព្រះជាម្ចាស់គង់នៅជាមួយបងប្អូនដែលត្រៀមខ្លួនទទួលពិធីជ្រមុជទឹក បងប្អូនដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាស បងប្អូនដែលត្រៀមខ្លួនតែងតាំងជាឧបដ្ឋាក និងអ្នកជំងឺទាំងអស់ដែលកំពុងមានទុក្ខវេទនាដោយសារកូវីដ១៩ និងដោយ

សារជំងឺនានា។ សេចក្តីក្លាហាន កម្លាំងរបស់ព្រះជាម្ចាស់ បន្តិចទៀតបានចូលនៅក្នុងប្រេងនេះ ដើម្បីហៀរចូលនៅក្នុងជីវិតរបស់យើង នៅក្នុងខ្លួនយើង ដើម្បីឲ្យយើងជាគ្រីស្តបរិស័ទត្រៀមខ្លួន ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូដែលរំដោះយើងពីអំពើបាប ពីភាពងងឹត ដើម្បីណែនាំឲ្យយើង ទៅរកជីវិត ជីវិតដ៏បរិបូរណ៍ ជីវិតអស់កល្បជានិច្ច។

យើងដឹងថាវត្តមានរបស់ប្រេងទាំងបី ប្រេងពិសិដ្ឋនៅថ្ងៃនេះ ជាសញ្ញាសម្គាល់បញ្ជាក់យ៉ាងច្បាស់អំពីវត្តមានរបស់ព្រះជាម្ចាស់នៅពេលនេះ នៅថ្ងៃនេះសម្រាប់យើង និងជាពិសេសរបៀបដែលព្រះជាម្ចាស់មានព្រះហឫទ័យយកចិត្តទុកដាក់ជាមួយយើង ដែលជាប្រជារាស្ត្រដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ យើងរស់នៅក្នុងពេលវេលាដែលយើងសង្ស័យយ៉ាងច្រើន នៅក្នុងពេលវេលាដែលយើងភ័យខ្លាច យើងព្រួយបារម្ភ។ បងប្អូនជាទីស្រឡាញ់ សូមមានសេចក្តីក្លាហាន កុំឲ្យជំនឿរបស់យើងធ្លាក់ចុះ ផ្ទុយទៅវិញ យើងដឹងថាព្រះយេស៊ូមិនកំពុងដេកលក់ ព្រះយេស៊ូនៅក្នុងខ្យល់ព្យុះដែលយើងមើលឃើញជុំវិញយើង ព្រះយេស៊ូនៅក្នុងជីវិតរបស់យើងផ្ទាល់។ ថ្ងៃនេះ ជាព្រះយេស៊ូផ្ទាល់ដែលទទួលប្រេងអភិសេក ដែលយាងមកដើម្បីព្យាបាលយើងទាំងអស់គ្នា ដើម្បីផ្តល់កម្លាំងសម្រាប់ជំនឿរបស់យើង ដើម្បីប្រទានសេចក្តីសង្ឃឹមឲ្យយើង ដើម្បីឲ្យសេចក្តីស្រឡាញ់របស់យើងរីកចម្រើនថែមទៀត។

ថ្ងៃអាទិត្យ យើងចូលក្នុងអាទិត្យពិសិដ្ឋ ដោយប្រារព្ធពិធីហែស្លឹក រងទុក្ខលំបាករបស់ព្រះយេស៊ូ។ បងប្អូនជាទីស្រឡាញ់ ខ្ញុំអញ្ជើញបងប្អូនទាំងអស់ ចូលរួមនៅក្នុងពេលវេលាដែលព្រះយេស៊ូរងទុក្ខលំបាក ព្រះយេស៊ូដែលជប់លៀងចុងក្រោយជាមួយក្រុមសាវ័ក និងព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញយ៉ាងជិតស្និទ្ធបំផុត។ ឆ្នាំនេះ យើងជួបជុំគ្នានៅតាមព្រះវិហារមិនបាន ប៉ុន្តែយើងបានរៀបចំឯកសារដែលយើងមានគ្រប់ពិធីបុណ្យ អត្ថបទ បទចម្រៀងដែលយើងចែកតាមគ្រួសារ តាមមធ្យោបាយផ្សព្វផ្សាយព័ត៌មានកាតូលិករបស់យើង ដូចជាហ្វេសបុក យូធូបតាមការថតចម្លងដែលយើងចែកតាមគ្រួសារ ដើម្បីចូលរួមជាមួយគ្នានៅក្នុងពេលវេលាពិសេសនៃព្រះសហគមន៍។ កុំឲ្យយើងបិទដួងចិត្តរបស់យើង ឲ្យយើងបើកដួងចិត្តរបស់យើងដល់ទុក្ខលំបាកនៃពិភពលោកទាំងមូល ដល់បងប្អូនដែលកំពុងស្លាប់ ដល់បងប្អូនដែលកំពុងភ័យ។

បងប្អូនជាទីស្រឡាញ់ ប្រហែលគ្រាអាសន្នណែនាំឲ្យយើងចូលនៅក្នុងផ្ទះរបស់យើងថែមទៀត មិនអាចធ្វើដំណើរ មិនអាចជួបជុំគ្នា ប៉ុន្តែកុំឲ្យយើងបោះចោលពេលវេលានេះ ឲ្យយើងយកពេលវេលានេះដើម្បីអធិដ្ឋាន ដើម្បីរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ នៅក្នុងជីវិតរបស់យើងផ្ទាល់។ ដោយសារព្រះជាម្ចាស់ស្រឡាញ់យើង និងប្រេងនេះជាសញ្ញាសម្គាល់យ៉ាងជាក់ស្តែងអំពីសេចក្តីស្រឡាញ់ សេចក្តីក្លាហានរបស់ព្រះជាម្ចាស់ចំពោះយើង។ ទីបញ្ចប់ ខ្ញុំសូមអធិដ្ឋានជា

ពិសេសសម្រាប់លោកបូជាចារ្យទាំងអស់ ដែលចូលនៅក្នុងអាទិត្យពិសិដ្ឋ នៅក្នុងរបៀបប្លែក។ យើងធ្លាប់យកចិត្តទុកដាក់រៀបចំពិធីបុណ្យយ៉ាងអស្ចារ្យ យ៉ាងស្អាត ដែលមានបទចម្រៀងពីរោះ ដែលមានភ្លេង ដែលមានផ្កា ដែលមានតុបតែង ដែលមានធម្មទេសនាពិសេស ដែលមានភ្លើង ដែលមានអ្វីៗទាំងអស់ ដែលណែនាំឲ្យយើងចូលនៅក្នុងទាំងជប់លៀងរបស់ព្រះយេស៊ូ ទាំងរងទុក្ខលំបាករបស់ព្រះយេស៊ូ ទាំងព្រះយេស៊ូរស់ឡើងវិញនៅក្នុងអំណរសប្បាយ ដោយសារសប្តាហ៍ពិសិដ្ឋជាកំពូលនៃជីវិតយើងជាបូជាចារ្យ។ ប៉ុន្តែឆ្នាំនេះ យើងមានអារម្មណ៍ថាយើងឯកោ ដោយសារយើងអភិបូជាម្នាក់ឯង ឬជាមួយគ្រីស្តបរិស័ទម្នាក់ឬពីរនាក់តាមច្បាប់ដែលយើងមាននៅខាងមុខនេះ។ ខ្ញុំសូមអញ្ជើញ លោកឪពុកទាំងអស់ដើម្បីណែនាំឲ្យពិធីបុណ្យនេះទៅជាពិធីបុណ្យអស្ចារ្យ ទោះបីម្នាក់ឯងក៏ដោយឲ្យយើងធ្វើដូចម្តេចឲ្យពិធីបុណ្យនីមួយៗ ទាំងលាងជើង ទាំងរងទុក្ខលំបាករបស់ព្រះយេស៊ូ ទាំងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនៅក្នុងថ្ងៃបុណ្យចម្លងទៅជាពិធីបុណ្យអស្ចារ្យមែនទែនសម្រាប់ជីវិតរបស់យើងជាបូជាចារ្យ ដែលយកចិត្តទុកដាក់រៀបចំដោយចិត្តគំនិត ដោយជំនឿ ដោយសេចក្តីស្រឡាញ់។ ប្រហែលយើងនៅម្នាក់ឯងជាខ្លួនរបស់យើងជារូបកាយរបស់យើង ប៉ុន្តែយើងដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើង និងជាពិសេសប្រជារាស្ត្ររបស់យើង គ្រីស្តបរិស័ទរបស់យើង ជំហានទី២ដែលទន្ទឹងរង់ចាំជីវិតពីយើង ការអធិដ្ឋានពីយើងនៅជាមួយយើងដែរ។ ដូច្នេះ យើងអាចនិយាយថា សប្តាហ៍ពិសិដ្ឋនេះយើងចូលរួមនៅក្នុងសក្ការបូជារបស់ព្រះយេស៊ូផ្ទាល់ខ្លួន ដើម្បីឲ្យជីវិតរបស់យើងទៅជាសក្ការបូជារួមជាមួយព្រះគ្រីស្ត និងដើម្បីឲ្យយើងណែនាំជីវិតដ៏បរិបូរណ៍ដល់បងប្អូនរបស់យើងទាំងអស់ រួមគ្នាយើងចូលនៅក្នុងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ដោយអធិដ្ឋាន។ អាម៉ែន៕